# ច្បាប់និងគោលនយោបាយពូជដំណាំនៃប្រទេសកម្ពុជា

រៀបចំដោយៈ នាយកដ្ឋានដំណាំស្រូវ/អគ្គនាយកដ្ឋានកសិកម្ម

២៩ វិច្ឆិកា ២០១៤

លោក គង់ សំអឿន

# ច្បាប់ស្តីពី

# ការគ្រប់គ្រងពូជដំណាំ និង សិទ្ធិអ្នកបង្កាត់ពូជដំណាំ

- អនុម័តដោយរដ្ឋសភានៅថ្ងៃទី ០៨ ខែមេសា ឆ្នាំ២០០៨
- អនុម័តដោយព្រឹទ្ធសភា នៅថ្ងៃទី២៩ ខែមេសា ឆ្នាំ២០០៨ ជាស្ថាពរ
- ចុះព្រះហស្តលេខាដោយព្រះនរោត្តម សីហមុនី នៅថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨
- ច្បាប់នេះមាន៩ជំពូក និង៨៤ មាត្រា។

# ជំពូកទី១
# បទប្បញ្ញត្តិទូទៅ

**មាត្រា១**

ច្បាប់នេះមានគោលដៅ គ្រប់គ្រង និងត្រួតពិនិត្យលើការបង្កាត់ ការបញ្ចេញឲ្យប្រើ ការផលិត ការកែច្នៃ ការចុះបញ្ជី ការចែកចាយ ការនាំចូល នាំចេញពូជដំណាំ និងការការពារពូជថ្មីនៃដំណាំក្នុងព្រះរាជាណាចក្រកម្ពុជា។

**មាត្រា២**

ច្បាប់នេះមានគោលបំណងធានានូវការគ្រប់គ្រង ការលើកទឹកចិត្ត និងការអភិវឌ្ឍន៍ពូជដំណាំដោយនិរន្តរភាព ដើម្បីផលប្រយោជន៍សង្គម សេដ្ឋកិច្ច និងបរិស្ថាន។

**មាត្រា៣**

ច្បាប់នេះមានវិសាលភាពអនុវត្តលើរាល់ពូជដំណាំ រួមទាំងពូជដំណាំដែលមានស្រាប់ និងពូជថ្មីនៃដំណាំលើកលែងតែការគ្រប់គ្រងដែលមានចែងក្នុងច្បាប់ពាក់ព័ន្ធផ្សេងទៀត។

**មាត្រា៤**

ការផ្តល់សិទ្ធិការពារពូជថ្មីនៃដំណាំត្រូវស្ថិតនៅក្រោមដែលសមត្ថកិច្ច នៃក្រសួងឧស្សាហកម្មរ៉ែ និងថាមពល។

ការគ្រប់គ្រងពូជដំណាំគ្រប់ប្រភេទត្រូវស្ថិតនៅក្នុងដែនសមត្ថកិច្ចទូទៅនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

**មាត្រា៥**

វាក្យស័ព្ទសំខាន់ៗ ដែលប្រើប្រាស់ក្នុងច្បាប់នេះ ត្រូវបានកំណត់ក្នុងឧបសម្ព័ន្ធនៃច្បាប់នេះ។

# ជំពូកទី២
# ការការពារពូជថ្មីនៃដំណាំ

## (មាត្រា៦ ដល់ មាត្រា៣៨)

**ពូជថ្មីនៃដំណាំ**

- ភាពថ្មី
  - ពុំមានលើទីផ្សារ ឬ
  - មិនលើស ១ឆ្នាំលើទីផ្សារកម្ពុជា(៦ឆ្នាំចំពោះដំណាំវល្លិនិង ដំណាំឈើ)
  - មិនលើស ៤ ឆ្នាំចំពោះគ្រប់ដំណាំផ្សេងទៀត (នៅក្រៅកម្ពុជា) ដោយគិតត្រឹមថ្ងៃដាក់ពាក្យសុំសិទ្ធិការពារ
- ភាពខុសប្លែក(D)
- ឯកសណ្ឋានភាព (U)
- ស្ថេរភាព(S)

**ការដាក់ពាក្យស្នើសុំសិទ្ធិការពាររបស់អ្នកបង្កាត់ពូជ**

**MIME & MAFF**

- ក្រសួងកសិកម្ម សិក្សាវាយតម្លៃ(DUS)
- ក្រសួងឧស្សាហកម្ម ចេញវិញ្ញាបនប័ត្រ ផ្លាស់ប្តូរម្ចាស់កម្មសិទ្ធិឬលុបចោល
- អ្នកដាក់ពាក្យ ចេញថ្លៃរដ្ឋបាល សេវា និងការថែរក្សាឯកសារ។

# ជំពូកទី៣
# ការគ្រប់គ្រងពូជដំណាំ

## (មាត្រា៣៩ ដល់ មាត្រា៥០)

**ពាណិជ្ជករ/អ្នកផលិត**

- សុំលិខិតអនុញ្ញាត
- ដាក់ពាក្យស្នើសុំវិញ្ញាបនប័ត្របញ្ជាក់គុណភាពគ្រាប់ពូជដំណាំ
- ទទួលខុសត្រូវគុណភាពគ្រាប់ពូជដំណាំ

**អ្នកប្រើប្រាស់**

**ក្រសួងកសិកម្ម**

- រៀបចំបញ្ជីពូជដំណាំ(មានស្រាប់និងថ្មី)
- ចេញលិខិតអនុញ្ញាតសម្រាប់ធ្វើពាណិជ្ជកម្មគ្រាប់ពូជដំណាំ
- ធ្វើតេស្តសាកល្បងគុណភាពគ្រាប់ពូជ
- ចេញវិញ្ញាបនប័ត្រ

ការតវ៉ា ដែលទាក់ទងគុណភាពគ្រាប់ពូជដំណាំ ត្រូវធ្វើឡើងក្នុងរយៈពេល៣០ថ្ងៃក្រោយពេលទិញ តែមុនពេលយកទៅសាប បណ្ដុះ ឬដាំ។

# ជំពូកទី៤
# អាហរណកម្ម នីហរណកម្ម និងការដឹកជញ្ជូនឆ្លងកាត់

## (មាត្រា៥១ ដល់ មាត្រា៦០)

### ក្រសួងកសិកម្ម

- អនុញ្ញាត ការនាំចេញនិងនាំចូល
- ការនាំចូលពូជដំណាំដែលបង្កគ្រោះថ្នាក់ត្រូវហាមឃាត់ និងកំណត់បញ្ជីឈ្មោះពូជដំណាំដែលគ្រោះថ្នាក់
- ដកហូតលិខិតអនុញ្ញាតនិងបញ្ឈប់ការនាំចេញនិងនាំចូល ក្នុងករណីរកឃើញថាពូជនោះពុំមានស្តង់ដារគុណ

### នាំចេញ

- មានលិខិតអនុញ្ញាតនាំចេញពី MAFF
- ជូនដំណឹងមកភ្នាក់ងារភូតគាមអនាម័យដែលនៅជិតបំផុតយ៉ាងតិច១ថ្ងៃនៃថ្ងៃធ្វើការមុនពេលពូជមកដល់ច្រកព្រំទ្វារនាំចេញនៃប្រទេសកម្ពុជា
- មានវិញ្ញាបនបត្របញ្ជាក់គុណភាពពូជដំណាំ
- បំពេញលក្ខខណ្ឌភូតគាមអនាម័យនៃប្រទេសនាំចូល

### នាំចូល

- មានការអនុញ្ញាតពី MAFF
- ជូនដំណឹងមក MAFF យ៉ាងតិច១០ថ្ងៃនៃថ្ងៃធ្វើការមុនពេលពូជដំណាំដល់ច្រកព្រំដែនកម្ពុជា
- បំពេញលក្ខខណ្ឌភូតគាមអនាម័យនៃព្រះរាជាណាចក្រកម្ពុជា។

### ដឹកជញ្ជូន

- មានវិញ្ញាបនបត្របញ្ជាក់គុណភាពពូជចេញដោយសមត្ថកិច្ចនៃប្រទេសនាំចេញ
- ជូនដំណឹង MAFF យ៉ាងតិច៥ថ្ងៃនៃថ្ងៃធ្វើការមុនពូជមកដល់ច្រកទ្វារនាំចូលដោយបញ្ជាក់កាលបរិច្ឆេតនិងច្រកទ្វារនាំចេញមកMAFF
- ធានាគុណភាពសុវត្ថិភាពសំបកវេចខ្ចប់ មធ្យោបាយផ្ទុកពូជនិងអនាម័យនៃមធ្យោបាយដឹកជញ្ជូន

# ជំពូកទី៥
# មូលនិធិជាតិអភិវឌ្ឍពូជដំណាំ

## (មាត្រា ៦១ ដល់ មាត្រា ៦៣)

MAFF

មូលនិធិជាតិអភិវឌ្ឍពូជដំណាំ

**ប្រភពមូលនិធិ**

- ថវិកាអំណោយរបស់រាជរដ្ឋាភិបាល
- អំណោយពីសប្បុរសជន សមាគមន៍ អង្គការ..
- ប្រាក់ពិន័យពីបទល្មើស
- កម្រៃសេវាកម្មផ្សេងៗ។

**គោលបំណង**

- ស្រាវជ្រាវបច្ចេកទេសជម្រើសពូជ
- ពិសោធន៍ឬសាកល្បងពូជដំណាំ
- ផ្សព្វផ្សាយអប់រំនិងបណ្តុះបណ្តាលបច្ចេកវិទ្យាពូជដំណាំ
- ចូលរួមជាសមាជិកអង្គការអន្តរជាតិពូជដំណាំ។

# ជំពូកទី៦
# ភ្នាក់ងារអធិការកិច្ចពូជដំណាំ

## (មាត្រា៦៤ ដល់ មាត្រា៦៨)

ក្រសួងកសិកម្មជា ភ្នាក់ងារនគរបាលយុត្តិធម៌

កិច្ចសហការ

- អាជ្ញាធរគ្រប់ជាន់ថ្នាក់ កងកម្លាំងប្រដាប់អាវុធ ស្ថាប័នគយ ....ក្នុងការជួយស្រាវជ្រាវ ទប់ស្កាត់ និងបង្ក្រាបបទល្មើសពូជដំណាំ
- ពេលបំពេញបេសកកម្មភ្នាក់ងារអធិការកិច្ចត្រូវស្លៀកពាក់ឯកសណ្ឋាន និងមានលិខិតបេសកកម្ម។

ភ្នាក់ងារអធិការកិច្ចពូជដំណាំមានភារកិច្ចដូចខាងក្រោម:

- តាមដាននិងត្រួតពិនិត្យលើការធ្វើអាជីវកម្មពូជដំណាំនៅកម្ពុជា
- ធ្វើអធិការកិច្ចគ្រប់ទីតាំងធ្វើអាជីកម្មពូជដំណាំទាំងក្នុងឃ្លាំងស្តុក ទីស្រែនិងកន្លែងផ្សេងទៀត
- ដកហូតបណ្ណោះអាសន្នរាល់លិខិតអនុញ្ញាត ពីអាជីវករដែលល្មើសច្បាប់
- មានសិទ្ធិឃាត់ឬបញ្ឈប់មធ្យោបាយដឹកជញ្ជូនពូជដំណាំដើម្បីត្រួតពិនិត្យ។

# ជំពូកទី៧
# ទោសប្បញ្ញត្តិ
## (មាត្រា ៦៩ ដល់ មាត្រា ៨១)

**បទល្មើសលើការការពារពូជថ្មីនៃដំណាំ**

- ➢ វិវាទ ដែលបានកើតឡើងពាក់ព័ន្ធទៅនឹងការនុវត្តជំពូក២ និងបទបញ្ញាទាំងឡាយត្រូវប្ដឹងទៅមន្ត្រីកាន់កាប់បញ្ជីការការពារពូជថ្មី
- ➢ ម្ចាស់សិទ្ធិពូជថ្មីនៃដំណាំ អាចប្ដឹងទៅតុលាការមានសមត្ថកិច្ចឲ្យជួសជុលសំណងតាមនិតិវិធីដូចជា ធ្វើបណ្ដឹងរដ្ឋប្បវេណី សុំការផាកពិន័យ សុំសងការខូចខាតជាទឹកប្រាក់
- ➢ បុគ្គលផ្ដល់ព័តមានមិនពិតត្រូវផាកពិន័យ ១លានរៀលទៅ៥លានរៀលឬដាក់គុក១ទៅ៦ខែ
- ➢ បុគ្គលដែលរំលោភដោយចេតនាលើសិទ្ធិការពារពូជថ្មីនៃដំណាំ ត្រូវផាកពិន័យជាប្រាក់ពី ៥ ទៅ២០ លានរៀលឬជាប់គុកពី១ទៅ៥ឆ្នាំ។

**បទល្មើសលើអាជីវកម្មពូជដំណាំ**

- ❖ ពិន័យអន្តរការណ៍ ការឃាត់ខ្លួនទុកវត្ថុតាង ការរឹបអូសវត្ថុតាង ការបំផ្លាញវត្ថុតាង ការតម្រូវឲ្យជួសជុលការខូចខាត ការដកហូតលិខិតអនុញ្ញាតធ្វើអាជីវកម្ម វិញ្ញាបនបត្របញ្ជាក់គុណភាពដំណាំ ទោសពិន័យនឹងទោដាក់ពន្ធនាគា
- ❖ ការអនុត្តពិន័យអន្តរការណ៍ ត្រូវកំណត់ដោយប្រកាសរបស់MAFF
- ❖ ប្រាក់លើកទឹកចិត្តនិងប្រាក់ពិន័យ ត្រូវកំណត់ដោយប្រកាសរួមរវាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនិងMAFF។

បទល្មើសដោយមន្ត្រីអនុវត្តច្បាប់

ភ្នាក់ងារអធិការកិច្ចដែលមានការធ្វេសប្រហែស ខ្វះការប្រុងប្រយ័ត្ន ឬមិនគោរពបទប្បញ្ញត្តិនេះ ត្រូវទទួលទណ្ឌកម្មខាងវិន័យរដ្ឋបាលនិង/ឬចោទប្រកាន់ចំពោះមុខតុលាការ។

## អន្តរប្បញ្ញត្ត

ពូជដំណាំដែលទទួលបានវិញ្ញាបនបត្របញ្ជាក់គុណភាពនិងលិខិតអនុញ្ញាតឲ្យធ្វើអាជីវកម្ម ពូជដំណាំ

ក្រោមបទប្បញ្ញត្តិផ្សេងៗ។ ត្រូវធ្វើនិយ័តកម្មស្របតាមច្បាប់នេះក្នុងរយៈពេលមិនលើសពី៦ ខែ គិត

ចាប់ពីកាលបរិច្ឆេទដែលច្បាប់នេះចូលជាធរមាន។

## ជំពូកទី៩
## អវសានប្បញ្ញត្ត

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍។